# កំណត់ហេតុ
# វេទិកាសិក្សារៀនសូត្រការគ្រប់គ្រងធនធានមនុស្សលើកទី៣៦
# ស្តីពី
# " ការអនុវត្តច្បាប់ការងារ "

*ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:០០នាទីរសៀល*

*នៅដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ*








*Prepared By: Ms. Keo Mara, Learning Specialist*
*Supported By: Ms. Sreng Sophorn Lakhena, Capacity Developmengt Assistant*

## I. សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាហៅកាត់ថា(គសក)គឺជាអង្គការសមាជិកភាពដែលបានបង្កើតឡើងដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០ ដោយបានដើរតួនាទីចំបងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព តម្លាភាព អភិបាលកិច្ច និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពចំពោះអង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការវិស័យផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។

ដើម្បីបន្តការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អង្គការសហគមន៍និងពង្រឹងសមត្ថភាពបន្ថែមអំពីអភិបាលកិច្ចល្អនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា អង្គការគសក បានអនុវត្តន៍បន្តនូវវេទិកាសិក្សារៀនសូត្រលើកទី៣៦នៃការគ្រប់គ្រងធនធានមនុស្សដោយផ្តែកលើប្រធានបទស្តីពី "*ការអនុវត្តច្បាប់ការងារ*"។

## II. គោលបំណងនៃវេទិកាសិក្សារៀនសូត្រ

- ដើម្បីរំលឹកមេរៀនពីមុនឡើងវិញក្នុងការជួយឲ្យសិក្ខាកាមពង្រឹងការទំនាក់ទំនងរវាងបុគ្គលិកនិងថ្នាក់គ្រប់គ្រងនៅក្នុងអង្គការរបស់ពួកគេ
- ដើម្បីលើកកម្ពស់សិក្ខាកាមយល់ច្បាស់អំពីការអនុវត្តច្បាប់ការងារ ដែលទាក់ទងទៅនឹងកញ្ចប់អត្ថប្រយោជន៍ផ្សេងៗរបស់បុគ្គលិក និងសៀវភៅការងារ(សម្រាប់បរទេស និងកម្ពុជា)
- ដើម្បីលើកកម្ពស់សិក្ខាកាមយល់ច្បាស់ពី កាតព្វកិច្ចនៃការអនុវត្តច្បាប់ធានារ៉ាប់រងផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនសម្រាប់អង្គការសង្គមស៊ីវិល
- ដើម្បីបង្កើតបរិយាកាសវេទិការៀនសូត្រនិងចែករំលែកក៏ដូចជាកសាងបណ្តាញឲ្យកាន់តែ មានភាពរឹងមាំក្នុងចំណោមអង្គការសង្គមស៊ីវិលនិងការទំនាក់ទំនងជាមួយមន្ត្រីពាក់ពន្ធ័កាន់តែមានប្រសិទ្ធភាព

## III. កិច្ចស្វាគមន៍ និង សន្ទរកថាបើកកម្មវិធី




**តាងនាមឲ្យអង្គការគសក លោក យន ប៊ុនថុង** ប្រធានផ្នែកប្រតិបត្តិការ បានធ្វើគារវកិច្ចដល់អង្គសិក្ខាកាមទាំងអង្គការដែលជាសមាជិក និងមិនមែនសមាជិកដែលមានវត្តមាននៅថ្ងៃនោះ។ ជាមួយគ្នានោះផងដែរ លោកបានរំលឹកអំពីសិក្ខាសាលាកាលពីខែមិនាដែលស្តីពីច្បាប់ពន្ធដារ គឺលោកបានលើកទឹកចិត្តដល់អង្គសិក្ខាកាមទាំងអស់ត្រូវតែចូលរួមគោរពនិងអនុវត្តន៍នូវភាពស្របច្បាប់ដែលបានចែង ដូចជាច្បាប់ការងារ និងសេវាកម្មរបស់របបបេឡាជាតិសន្តិសុខសង្គម រួមទាំងការរៀបចំឯកសារច្បាប់ពាក់ព័ន្ធ ក្នុងចុះបញ្ជី ត្រូវតែមានភាពសមស្របទៅតាមច្បាប់ ។

លោកបានបន្តទៀតថាដូចជាវេទិកាសិក្សារៀនសូត្រថ្ងៃនេះមានសារៈសំខាន់ណាស់គឺបានផ្តោតលើ **កាតព្វកិច្ចនៃការអនុវត្តច្បាប់រួមមានៈ ធានារ៉ាប់រងផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងកញ្ចប់អត្ថប្រយោជន៍ផ្សេងៗសម្រាប់បុគ្គលិកអង្គការសង្គមស៊ីវិល និងសៀវភៅការងារ (សម្រាប់បរទេស និងកម្ពុជា)** ។ លោកបន្តទៀតថាយើងនឹងដឹងច្បាស់អំពី ការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសនិងបណ្ណ/សៀវភៅការងារជនបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការ គសក បានព្យាយាមគ្រប់មធ្យោបាយក្នុងការជួយសម្រួលដល់អង្គការសមាជិករបស់ខ្លួន ដូចជាបានចុះអនុសារណៈជាមួយអង្គការដៃគូគឺអង្គការ LAC នឹងក្រុមហ៊ុន FIDL ដើម្បីជួយផ្តល់ប្រឹក្សាផ្នែកច្បាប់និងពន្ធដារក្នុងការអនុវត្ត

ច្បាប់ក្នុងវិស័យអង្គការសង្គមស៊ីវិលដែលនៅក្នុងប្រទេសកម្ពុជាកាន់តែយល់ច្បាស់អំពីច្បាប់និងការអនុវត្តច្បាប់តាមរយៈក្រុមការងារបច្ចេកទេសរបស់អង្គការគសក មាន LAC នឹង ក្រុមហ៊ុន FIDL ។

លោកបន្តថានៅក្នុងឆ្នាំ២០១៧ អង្គការគសក បានស្នើសុំទៅក្រសួងពន្ធដារដើម្បីបង្កើតក្រុមការងារផ្នែកពន្ធដារនៅក្នុងក្រសួងដើម្បីងាយស្រួលក្នុងធ្វើការជាមួយមន្ត្រីដែលចំជំនាញដើម្បីឆ្លើយតបបានទាន់ពេល។ លើសពីនេះទៅទៀត គសក ក៏បានអញ្ជើញវាគ្មិនមកពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីជួយឲ្យអង្គការសង្គមស៊ីវិលកាន់តែយល់ច្បាស់អំពីការផ្តល់សេវាកម្ម និងការចុះបញ្ជីពាក់ព័ន្ធនានា។ លោកក៏បានលើកផងដែរថាការប្រើសេវាកម្មរបស់**បសសក៏**ជាផ្នែកមួយក្នុងការអភិវឌ្ឍស្ថាប័នឲ្យកាន់តែប្រសើរផងដែរ ម្យ៉ាងទៀតវាមិនបាច់ចាំប្រើប្រាស់សេវាកម្មសុខភាពរបស់ក្រុមហ៊ុនឯកជន ។ ជាមួយគ្នានោះលោកបានប្រកាសជូនដំណឹងដល់សមាជិកទាំងអស់ដែលអង្គការគសកនឹងមានវគ្គសិក្ខាសាលាដែលទាក់ទងច្បាប់ការងារនិងច្បាប់ពន្ធដារដល់ថ្នាក់មូលដ្ឋាន ក៏ដូចជាចុះទៅតាមបណ្តាញថ្នាក់ខេត្តមួយចំនួនដូចជា កំពង់ចាម កំពត និងបាត់ដំបង។ ជាចុងបញ្ចប់លោកក៏បានប្រកាសបើកវេទិកាសិក្សារៀនសូត្រនោះទៅតាមពេលវេលានិងរបៀបវារៈដែលបានគ្រោងទុក។

## IV. លទ្ធផលសង្ខេបនៃវេទិកាសិក្សារៀនសូត្រ

វេទិកាសិក្សារៀនសូត្រនេះប្រារព្ធឡើងពេញមួយថ្ងៃនៅថ្ងៃទី២៥ខែមេសាឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានអ្នកចូលរួមសរុប**១៩៥នាក់(ស្ត្រី៧៦នាក់)**។ ក្នុងចំណោមសិក្ខាកាមនោះរួមមានៈ៣៨អង្គការអន្តរជាតិ , ៣០អង្គការជាតិ, ១ក្រុមហ៊ុន, ៥៧អង្គការសមាជិក ១០អង្គការមិនមែនសមាជិក និង វាគ្មិនកិត្តិយសតំណាងអញ្ជើញមកក្រសួងការងារ២រូប និង មកពីបេឡាជាតិរបបសន្តិសុខសង្គមចំនួនពីររូបផងដែរ។

## វគ្គទី១ ការរំលឹកឡើងវិញអំពីមេរៀននៃវេទិកាសិក្សារៀនសូត្រលើកមុន ស្តីពី "ការទំនាក់ទំនងគ្នាទៅវិញទៅមករវាងបុគ្គលិក និង ថ្នាក់គ្រប់គ្រង"

ដើម្បីជាជំនួយស្មារតីក្នុងការចងចាំមេរៀនដែលបានរៀនកាលពីចុងឆ្នាំ២០១៧ **អ្នកស្រី សៀង សត្យា** អ្នកឯកទេសគ្រប់គ្រងធនធានមនុស្ស អង្គការគសក បានសង្ខេបនិងពន្យល់អង្គសិក្ខាកាមឡើងវិញនូវមេរៀនកាលពីឆ្នាំទៅដែលស្តីពី "ការទំនាក់ទំនងគ្នាទៅវិញទៅមករវាងបុគ្គលិក និង ថ្នាក់គ្រប់គ្រង" ដូចដែលមានមាតិកាសំខាន់នៅក្នុងបទបង្ហាញ។

1. **តើការទំនាក់ទំនងគ្នាទៅវិញទៅមករវាងបុគ្គលិក និង ថ្នាក់គ្រប់គ្រង ជាអ្វី?**
2. **តើមានសមាសធាតុអ្វីខ្លះនៅក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមករវាងបុគ្គលិក និង ថ្នាក់គ្រប់គ្រង?**
3. **តើមានបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមករវាងបុគ្គលិក និង ថ្នាក់គ្រប់គ្រង?**
4. **តើគោលនយោបាយផ្ទៃក្នុងជាអ្វី?**
5. **តើសរសេរគោលនយោបាយផ្ទៃក្នុងជាអ្វីដូចម្តេច?**
6. **ករណីសិក្សាស្តីពី គោលនយោបាយជ្រើសរើសអតីតបុគ្គលិក**
7. **យន្តការបណ្តឹង**
8. **ករណីសិក្សាស្តីពី យន្តការបណ្តឹង**

## វគ្គទី២ មតិស្វាគមន៍ តំណាងដ៏ខ្ពង់ខ្ពស់នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ





ដើម្បីបន្តនូវកម្មវិធីបន្ទាប់ដែលទាក់ទងទៅនឹងច្បាប់ការងារ **លោក ហេង ហ៊ត អនុប្រធាននាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម** បានឡើងថ្លែងមតិស្វាគមន៍និងថ្លែងអំណរគុណដល់អង្គការគសកនិងសហការីទាំងអស់ដែលបានរៀបចំមានវេទិកានេះឡើង លោកក៏ថ្លែងអំណរគុណដល់ក្រុមការ ងារស្ម័គ្រចិត្តទាំងអស់របស់អង្គការ គសក ម្ចាស់ជំនួយដៃគូរអភិវឌ្ឍន៍និងអង្គសិក្ខាកាមរួមទាំងអង្គការសមាជិកនិងមិនមែនសមាជិកដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមនៅក្នុងវេទិកាសិក្សារៀនសូត្រនេះ។

ក្នុងពេលនោះលោកបានចែករំលែកដល់អង្គសិក្ខាកាមដែលទាក់ទងទៅនឹងច្បាប់ការងារ ដោយលោកផ្តោតទៅលើមាត្រាសំខាន់ៗមួយចំនួនដែលមានការពាក់ព័ន្ធជាមួយការអនុវត្តច្បាប់របស់អង្គការសង្គមស៊ីវិលដើម្បីឲ្យកាន់តែយល់ដឹងច្បាស់ដូចជា:

- **មាត្រា១ មាត្រា២ មាត្រ៣២ និងមាត្រា៦១ នៃច្បាប់ការងារ**

លោកក៏បានលើកបន្ថែមទៀតថាច្បាប់ការងារសម្រាប់ជនបរទេសគឺទិដ្ឋាការមាន៧ប្រភេទដូចមានចែងនៅក្នុងច្បាប់ក្រសួងមហាផ្ទៃ។ មិនត្រឹមតែប៉ុណ្ណោះលោកបានជម្រុញនិងលើកទឹកចិត្តប្រជាពលរដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ចចុះបញ្ជីសៀវភៅការងាររបស់ជនបរទេស និង ខ្មែរតាមនីតិវិធីច្បាប់ដែលបានចែង។ លកក៏បានបន្ថែមផងដែរថា ប្រសិនបុគ្គលិកជាជនបរទេស(ពេញសិទ្ធ)ចេញ ឬចូលនៅក្នុងស្ថាប័នយើង គឺយើងត្រូវជូនដំណឹងទៅក្រសួងការងារឲ្យបានមុន ឬ ក្រោយ (ចេញចូលគម្រោងការងារ) រយះពេល ១០ថ្ងៃ ។ ហើយបើសិនជនបរទេសនៅតាមខេត្តគឺត្រូវជូនដំណឹងនោះទៅមន្ទីរខេត្ត។ ហើយប្រសិនជាបុគ្គលិកខ្មែរដែលពេញសិទ្ធិ ហើយមានការ ចេញ ឬចូល(ចលនាបុគ្គលិក) ស្ថាប័ននោះត្រូវជូនដំណឹងទៅក្រសួងការងារឲ្យបានមុន ឬ ក្រោយក្នុងរយះពេល ៧ថ្ងៃ តាមសៀវភៅនៃច្បាប់កាងារ (មាត្រាទី ២១)។

ដើម្បីឲ្យអង្គសិក្ខាកាមកាន់តែយល់ច្បាស់ពីនិតិវិធីផ្សេងៗដែលទាក់ទងទៅនឹងការចុះបញ្ជីសៀវភៅការងារ លោកបានប្រគល់តួនាទីនោះបន្តទៅ **លោក ស៊ឹម ហុង អនុប្រធាននាយកដ្ឋានមុខរបរ និង ហត្ថពលកម្មដែលមកពីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ** ដើម្បីឡើងធ្វើបទបង្ហាញសេចក្តីណែនាំស្តីពីការស្នើសុំការអនុញ្ញាត្តប្រើប្រាស់ហត្ថពលកម្មបរទេសនិងបណ្ណ/សៀវភៅការងារជនបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈប្រព័ន្ធវេបសាយៈ https://fwcms.mlvt.gov.kh/។ ហើយលោកបានបន្ថែមថា ប្រជាជនកម្ពុជាដែលចូលធ្វើការនៅស្រុកខ្មែរត្រូវតែចុះឈ្មោះក្នុងក្រសួងហើយអាចធ្វើការចុះឈ្មោះជាដំណាក់កាលនីមួយៗតាមប្រព័ន្ធវេបសាយរបស់ក្រសួង ។

ទន្ទឹមនឹងនោះ លោកវាគ្មិនទាំងពីររូបក៏បានប្រកាស ក៏ដូចជាធ្វើការសំនូមពរដល់អង្គសិក្ខាកាម រឺ អង្គការសង្គមស៊ីវិលទាំងអស់គួរមានសៀវភៅច្បាប់ៗផ្សេងនៅកន្លែង និង ហើយអានឲ្យយល់ដើម្បីមានភាពងាយស្រួយក្នុងការអនុវត្តការងារ ជាពិសេសលោកស្នើឲ្យអង្គការ គ ស ក ដាក់លិខិតស្នើរសុំឯកសារពីក្រសួងការងារឬទំនាក់ទនងលោកផ្ទាល់ ដើម្បីចែករំលែកទៅដល់អង្គការសង្គមស៊ីវិលទាំងអស់ដែលបានចូលរួមក្នុង

វេទិកាសិក្សារៀនសូត្រនេះ។ *សូមមើលខ្លឹមសារដើមទាំងស្រុងនៃបទបង្ហាញនោះនៅក្នុងវេបសាយរបស់អង្គការគេសក។*

## វគ្គទី៣ : បទបង្ហាញស្តីពី "ការអនុវត្តច្បាប់ស្តីពី បេឡាជាតិរបបសន្តិសុខសង្គម"




**ឯកឧត្តម ស៊ុំ សោភ័ណ នាយករង បេឡាជាតិ របបសន្តិសុខសង្គម** លោកបានថ្លែងអំណរគុណដល់អង្គការគេសកដែលបានអញ្ជើញឯកឧត្តម មកធ្វើជាវាគ្មិនក្នុងការចែករំលែកច្បាប់ដែលទាក់ទងទៅនឹងបេឡាជាតិរបបសន្តិសុខសង្គម និងចូលរួមជួយការងារមួយដល់រដ្ឋាភិបាលផងដែរ។ ឯកឧត្តមបានស្នើដល់អង្គសិក្ខាកាមព្យាយាមស្តាប់ដើម្បីចូលរួមបំពេញនូវភាពខ្វះចន្លោះរបស់សង្គមស៊ីវិលទាំងមូល ក៏ដូចជាចូលរួមជួយកែតម្រូវបែបស្ថាបនាដល់សេវាបេឡាជាតិរបបសន្តិសុខសង្គមផងដែរ ។ ក្នុងពេលនោះឯកឧត្តម **បាន**បន្តធ្វើបទបង្ហាញនិងចែករំលែកដល់អង្គសិក្ខាកាម ឲ្យបានយល់នូវការអនុវត្តច្បាប់ស្តីពី បេឡាជាតិរបបសន្តិសុខសង្គមដែលមានមាតិកាសំខាន់ៗដូចជាៈ

1. **សេចក្តីណែនាំអំពីរបបសន្តិសុខសង្គម**
2. **ប្រភេទនៃកញ្ចប់សុខភាព**
3. **ច្បាប់ធានារ៉ាប់រងផ្នែកហានិភ័យការងារ**
4. **ផ្នែកប្រាក់សោធននិវត្ត**

ឯកឧត្តមក៏បានលើកឡើងថាការបង្កើតប័ណ្ណបសសគឺជាបច្ច័យល្អដែលយើងអាចប្រើប្រាស់បសស បានល្អប្រសើរទាំងអស់គ្នាទោះបីការប្រើប្រាស់នោះមិនទាន់បានមួយរយភាគរយក៏ដោយ ឯកឧត្តម បានលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលបន្តការប្រើប្រាស់សេវាបសស ដើម្បីជួយសម្រួលនិងជួយស្ថាបនាសេវាកម្មឲ្យកាន់តែល្អប្រសើរឡើងវិញ។

*ព័ត៌មានលំអិតមាននៅក្នុងបទបង្ហាញដែលបានថតចម្លងនិងផ្តល់ជូនជាឯកសារ ឬអាចរកបាននៅក្នុងគេហទំព័ររបស់បសស។*



ក្រោយពីលោកវាគ្មិនបានបញ្ចប់នូវបទបង្ហាញនោះ សិក្ខាកាមមួយចំនួនមានសំនួរដែលទាក់ទងនឹងការការអនុវត្តការងារក៏ដូចជាព័ត៌មានផ្សេងៗបានលើកឡើងជូនដល់លោកវាគ្មិនដើម្បីជួយស្រាយបំភ្លឺឲ្យកាន់តែយល់ច្បាស់ ។ សំនួរនិងចម្លើយនឹងមានភ្ជាប់នៅឧបសម្ព័ន្ធ។

*យោងតាមពេលវេលាមិនអំណោយផល សំនួរមួយចំនួនដែលលោកវាគ្មិនមិនទាន់បានឆ្លើយតបអស់ គឺស្នើឲ្យអង្គការគេសកដាក់លិខិតស្នើសុំបំណកស្រាយជាលាយលក្ខណ៍អក្សរ ពីវាគ្មិនផ្ទាល់ ។*

## វគ្គទី៤ លទ្ធផលនៃការវាយតម្លៃបញ្ចប់វគ្គវេទិកាសិក្សារៀនសូត្រ

តារាងខាងក្រោមនេះនឹងបង្ហាញនូវលទ្ធផលនៃវគ្គសិក្សារៀនសូត្រក្នុងរយៈពេលមួយថ្ងៃពេញ

| ប្រធានបទ | មិនពេញចិត្តទាល់តែសោះ (%) | មិនពេញចិត្ត (%) | ធម្មតា (%) | ពេញចិត្ត (%) | ពេញចិត្តខ្លាំងណាស់ (%) |
|---|---|---|---|---|---|
| ទីកន្លែង | 0% | 0% | 1% | 71% | 28% |
| ការផ្តល់ជូនផ្នែកភស្តុភា | 0% | 0% | 12% | 71% | 17% |
| ការយល់ដឹងរបស់សិក្ខាលើមេរៀននិងខ្លឹមសារនៃមាតិកាសំខាន់ៗ | 0% | 0% | 10% | 71% | 19% |
| វិធីសាស្ត្រនៃការពន្យល់របស់វាគ្មិន | 0% | 0% | 19% | 50% | 31% |
| ការចែករំលែកបទពិសោធន៍របស់វាគ្មិន | 0% | 0% | 10% | 62% | 28% |
| រយៈពេល | 2% | 7% | 24% | 60% | 7% |

▶ ***ចំណុចសំខាន់ៗមួយចំនួនដែលសិក្ខាកាមចាប់បានច្បាស់ល្អពីវគ្គវេទិកានេះមានដូចជា៖***

- បានយល់កាន់តែច្បាស់ពីអត្ថប្រយោជន៍ ប.ស.ស
- អត្ថប្រយោជន៍នៃការកសាងស្នាដៃការងារ សម្រាប់អង្គការសង្គមស៊ីវិល
- កាតព្វកិច្ចនៃការចុះបញ្ជីសៀវភៅការងាររបស់ជនបរទេស និង ខ្មែរតាមនីតិវិធីច្បាប់
- យល់ដឹងពីការបំពេញការងារស្របច្បាប់នៅក្នុងវេសសាយរបស់ក្រសួង
- បានយល់ពីរបៀបធ្វើ**Visa**ប្រភេទ **B &C**
- វគ្គនេះសិក្ខាសាលានេះធ្វើបានល្អមានការចាប់អារម្មខ្លាំងបំផុត ហើយចាំបាច់ត្រូវតែយល់ច្បាស់លាស់សម្រាប់គ្រប់គ្នា។

▶ ***ចំណុចសំខាន់ៗដែលនឹងត្រូវបានយកទៅអនុវត្តន៍ដើម្បីឲ្យជំនាញនិងការអនុវត្តការងារនៅក្នុងអង្គការរបស់គេកាន់តែប្រសើរឡើង៖***

- ចែករំលែកគោលនយោបាយចូលនិវត្តន៍
- ផ្សព្វផ្សាយអំពីផលប្រយោជន៍របស់ បសសដល់បុគ្គលិកទាំងអស់
- នឹងពិគ្រោះជាមួយបុគ្គលិកថ្នាក់គ្រប់គ្រងក្នុងការអនុវត្តច្បាប់ដូចជា សៀវភៅការងារ និង អត្ថប្រយោជន៍សៀវភៅការងារសម្រាប់បុគ្គលិក ដើម្បីអោយមានភាពល្អប្រសើរ
- ផ្តល់ពត៌មានដល់បុគ្គលិកអំពីការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសនិង បណ្ណ/សៀវភៅការងារជនបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

▶ ***ចំណុចសំខាន់ៗដែលសិក្ខាកាមនឹងចែករំលែកបន្តទៅអ្នកផ្សេងទៀត***

- អត្ថប្រយោជន៍នៃការកសាងស្នាដៃការងារ និងសៀវភៅ ការងារសម្រាប់បុគ្គលិក
- លើកទឹកចិត្តឲ្យគេប្រើសេវាកម្មបសសដើម្បីទទួលអត្ថប្រយោជន៍ពីសេវាបសសសម្រាប់បុគ្គលិក

## សេចក្តីសន្និដ្ឋាន និង ការចែករំលែកករណីសិក្សា

យោងតាមលទ្ធផលនៃការវាយតម្លៃវគ្គវេទិកាសិក្សារៀនសូត្រនេះបានបង្ហាញថា ជារួមសិក្ខាកាមទាំងអស់មានការចាប់អារម្មណ៍និងពេញចិត្តនៅក្នុងវគ្គវេទិកាសិក្សារៀនសូត្រនេះ រួមមាន ទីកន្លែង ការផ្តល់ភស្តុភា ជាពិសេសពួកគេពេញចិត្តនូវវិធីសាស្រ្ត និងការចែករំលែកបទពិសោធន៍របស់វាគ្មិនដែលបានពន្យល់នូវខ្លឹមសារមេរៀនបានច្បាស់លាស់ និងបានបានជួយដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលទាក់ទងក្នុងការអនុវត្តសៀវភៅការងារនៅក្នុងអង្គការរបស់ពួកគេ។ សិក្ខាកាមយល់កាន់តែច្បាស់នូវការអនុវត្តច្បាប់ បសស និង កូតា ដែលទាក់ទងនឹងការងាររបស់ពួកគេដូចជាប្រភេទនៃកញ្ចប់ សុខភាពច្បាប់ធានារ៉ាប់រងផ្នែកហានិភ័យការងារ កាតព្វកិច្ច ការចុះបញ្ជី ដែលអង្គការត្រូវតែអនុវត្តន៍ជាដើម។ ជាងនេះទៀតនោះ សិក្ខាកាមទាំងនោះក៏មានការតាំងចិត្តយកចំណេះដឹងនេះទៅចែករំលែកដល់បុគ្គលិករបស់ខ្លួន និងអនុវត្តន៍ច្បាប់ទាំងនោះនៅក្នុងអង្គការរបស់ពួកគេឲ្យកាន់តែប្រសើរឡើងផងដែរ។

លើសពីនេះទៅទៀត មានការចាប់អារម្មណ៍ច្រើនដល់អ្នកចូលរួមភាគច្រើនជាពិសេសថ្នាក់ប្រតិបត្តិ ឬ អ្នកគ្រប់គ្រងក្នុងគោលបំណងបង្កើនសមត្ថភាពរបស់ពួកគេ។ ទន្ទឹមនឹងនេះដែរសិក្ខាកាមបានចូលរួមក្នុងការចែករំលែកករណីសិក្សា និងបទពិសោធន៍ដែលទាក់ទងជាមួយនឹងការប្រើប្រាស់សេវាកម្មសាធារណៈឬសេវាបសស។ ជាពិសេសសិក្ខាកាមទាំងនោះបានយល់ច្បាស់ពីអត្ថប្រយោជន៍បសសនិងសៀវភៅការងារ គឺពួកគេបានតាំងចិត្តក្នុងការអនុវត្តច្បាប់នៅក្នុងអង្គការរបស់ពួកគេ។ លើសពីនេះទៀត លទ្ធផលនៃការវាយតម្លៃនៃវេទិកាសិក្សារៀនសូត្រសាលាបានផ្តល់លទ្ធផលគួរឱ្យពេញចិត្តបន្ថែមទៀត។ សិក្ខាសាលាបណ្តុះបណ្តាលនេះមិនត្រឹមតែជាឱកាសដើម្បីលើកកំពស់សមត្ថភាពរបស់ពួកគេប៉ុណ្ណោះទេប៉ុន្តែឱកាសមួយក្នុងការពង្រឹងការទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិលនិងមន្ត្រីរដ្ឋាភិបាលកាន់តែប្រសើរឡើង។

## មតិបិទកម្មវិធីវេទិកាសិក្សារៀនសូត្រ

នៅចុងកម្មវិធីនៃវេទិកាសិក្សារៀនសូត្រនេះ **ឯកឧត្តម ស៊ុំ សោភ័ណ** បានផ្តាំផ្ញើរនិងលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ប្រើប្រាស់សេវាកម្មរដ្ឋប្រសើរជាជាងការប្រើប្រាស់សេវាឯកជន ពីព្រោះសេវាកម្មរដ្ឋមានឧបករណ៍គ្រប់គ្រាន់។ ប្រសិនបើយើងចូលរួមប្រើសេវាកម្មទាំងអស់គ្នានោះនឹងធ្វើឲ្យការផ្តល់សេវាកាន់តែមានភាពល្អប្រសើរឡើង។ ទោះបីឥឡូវនេះសេវាកម្មរដ្ឋមានការយឺតយ៉ាងក៏ដោយក៏យើងត្រូវតែចូលរួមជួយផ្តល់នូវការកែលម្អនិងស្ថាបនាទៅដល់ស្ថាប័នរដ្ឋដើម្បីឱ្យមានការអភិវឌ្ឍកាន់តែប្រសើរឡើងជាងនេះទៅទៀត។

ជាមួយគ្នានោះ លោក យន ប៊ុនថុង ក៏បានឡើងថ្លែងអំណរគុណជាថ្មីម្តងទៀតដល់អង្គសិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលាមកចូលរួម និងយកចិត្តទុកដាក់រៀនសូត្រពេញមួយថ្ងៃ ជាពិសេស លោកក៏ថ្លែងអំណរគុណដល់លោកវាគ្មិនកិត្តិយសទាំងអស់ដែលបានលះបង់ពេលវេលាដ៏មមាញឹករបស់លោកដើម្បីចូលរួមចែករំលែកនូវចំណេះដឹងដែលទាក់ទងទៅនឹងការអនុវត្តច្បាប់បសស និង ច្បាប់ការងារសំដៅធ្វើយ៉ាងណាឲ្យអង្គការសង្គមស៊ីវិលបានយល់ដឹងនិងអនុវត្តន៍ច្បាប់កាន់តែប្រសើរឡើង។

# ឧបសម្ព័ន្ធ

## ▶ សំនួរនិងចម្លើយដែលទាក់ទងជាមួយនឹងសៀវភៅការងារ

1. **សំនួរ:** បើសិនជាបំពេញឯកសារនៅក្នុងប្រព័ន្ធមិនទាន់គ្រប់តើយើងអាចរក្សាឯកសារសិនបានទេ?
   **ចម្លើយ:** បាន ហើយវាគ្មិនបានបង្ហាញពីរបៀបរក្សាទុកឯកសារលើវេបសាយរបស់ក្រសួង

2. **សំនួរ:** ចំពោះបុគ្គលិកដែលទទួលបានវីសាប្រភេទ B ហើយចង់ផ្លាស់ប្តូរទៅប្រភេទ C តើការផ្លាស់ប្តូរនេះវាត្រឹមត្រូវហើយសមស្របទៅនឹងប្រយោជន៍នៃការងារដែរឬទេ?
   **ចម្លើយ:** ត្រឹមត្រូវ

3. **សំនួរ:** តើសៀវភៅការងារវាមានផលប៉ះពាល់អ្វីខ្លះ ប្រសិនបើបណ្ណការងារនោះធ្វើមកមានខុសព័ត៌មាន ?
   **ចម្លើយ:** បើខុសព័ត៌មាន ត្រូវតែកែប្រែ ហើយកំហុសវាអាចទាំងពីរគឺកំហុសខាងអង្គការផងកំហុសខាងរដ្ឋាភិបាលផង ដោយសារមន្ត្រីនោះមិនបានផ្សព្វផ្សាយឱ្យបានពេញលេញអំពីការធ្វើសៀវភៅការងារ និង អត្ថប្រយោជន៍នៃសៀវភៅការងារនោះ។ យើងគួរតែពិភាក្សាជាមួយមន្ត្រីដែលបានចុះបញ្ជីការងារឲ្យបានច្បាស់លាស់ដើម្បីធ្វើសៀវភៅកាងារក៏ដូចជាការកែតម្រូវសៀវភៅការងារឡើងវិញ។

4. **សំនួរ:** តើការប្តូរ ទិដ្ឋកា E ទៅ ទិដ្ឋកា NGO ធ្វើតាមរបៀបណា ?
   **ចម្លើយ:** ធ្វើការស្នើសុំទៅមន្ទីរពាក់ព័ន្ធដើម្បីឲ្យគេជួយក្នុងរឿងធ្វើ ទិដ្ឋកានេះ។ របៀបធ្វើ គឺអង្គការដែលបានចុះកិច្ចព្រមព្រៀងគម្រោងការងារថ្មីៗនិងប្រតិបត្តិការរបស់អង្គការ ឲ្យគេរៀបចំទៅខាងក្រសួងការបរទេសសុំ ទិដ្ឋកា ដើម្បីស្នាក់នៅកម្ពុជានូវទម្រង់គម្រូ។ ប្រសិនបើយើងមានទិដ្ឋការនៅក្រសួងមហាផ្ទៃហើយ មានន័យថាយើងចុះបញ្ជីរួចរាល់ហើយមិនចាំបាច់ចុះទៀតទេ។

5. **សំនួរ:** តើអ្នកស្ម័គ្រចិត្តបរទេសត្រូវមានប័ណ្ណការងារដែរឬទេ?ប្រសិនបើមានតើប្រភេទ អ្វីខ្លះ?
   **ចម្លើយ:** សូមពិនិត្យមើលនៅក្នុងអនុក្រឹត្យ123 របស់ក្រសួងមហាផ្ទៃដែលចេញថ្មីដែលបានចែងអំពីប្រភេទទិដ្ឋាកានេះ ។ ទិដ្ឋាការនៅកម្ពុជាមាន 7 ប្រភេទគឺ ទិដ្ឋកា A និង B គឺទិដ្ឋិកាកាទូតហើយប្រភេទទិដ្ឋកា C សម្រាប់បរទេសដែលចេញចូលតាមទេសចរណ៍។

6. **សំនួរ:** បើគាត់ជាជនបរទេសហើយមានអត្តញ្ញាណប័ណ្ណខ្មែរ ហើយគាត់មានសិទ្ធិធ្វើសៀវភៅការងារ តើគាត់ធ្វើជាភាសាខ្មែរ ឬជាភាសាបរទេស? ហើយធ្វើនៅឯណា?
   **ចម្លើយ:** បើរស់នៅក្នុងប្រទេសកម្ពុជាគឺត្រូវអនុវត្តន៍តាមច្បាប់ប្រទេសទាំងអស់

7. **សំនួរ:** តើមានសេចក្តីប្រកាសណាមួយដែលនិយាយអំពីការលើកលែងទិដ្ឋកាABC?
   **ចម្លើយ:** តាមច្បាប់ការងារមាត្រាទី១ និង អនុក្រឹត្យលេខ១២៣(សូមអានបន្ថែមលើច្បាប់)

8. **សំនួរ:** នៅពេលដែលក្រសួងមហាផ្ទៃចុះមកត្រួតពិនិត្យជនបរទេសដែលធ្វើការនៅក្នុងអង្គការ តើគួរតែរៀបចំឯកសារអ្វីខ្លះ?
   **ចម្លើយ:** ជាទូទៅការចុះត្រួតពិនិត្យគឺមានក្រុមមន្ត្រីចម្រុះនិងធ្វើអធិការកិច្ចដែលមានរៀបចំឯកសារត្រឹមត្រូវហើយមានការជូនដំណឹងមុនក្នុងការចុះបេសកកម្មរបស់ពួកគាត់។

## ▶ សំនួរនិងចម្លើយទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គម

9. **សំនួរ:** តើអតីតភាពការងារជាង 20 ឆ្នាំ ទទួលបានកញ្ចប់សោធនដែរឬទេ?
**ចម្លើយ:** បសសមានគោលការណ៍តែមួយ ដែលទាក់ទងជាមួយនឹងអង្គការ ។ បសសនឹងរាប់បញ្ចូលពេលវេលាដែលបានបង់វិភាគទានចូលទៅបសសហើយនិងបានចុះបញ្ជីជាមួយបសស ទោះបីជាអតីតភាពការងារប៉ុន្មានឆ្នាំក៏ដោយឲ្យតែនៅធ្វើការក្នុងអង្គការដដែលតែមួយ គឺយើងអាចទទួលបានប្រាក់សោធននោះ។ ក៏ប៉ុន្តែប្រសិនបើយើងផ្លាស់ប្តូរ អង្គការ ហើយទើបតែចាប់ផ្តើមធ្វើសៀវភៅ នោះ បសសនឹងគិតទៅតាមគោលការណ៍ដែលបានចែង ។

10. **សំនួរ:**តើរវាងនិយោជិកនិងនិយោជកត្រូវបង់វិភាគទានប៉ុន្មានភាគរយ? ហើយចំពោះស្ត្រីមានផ្ទៃពោះដែលសម្រាកលំហែមាតុភាព តើទទួលបាន៧០%នៃប្រាក់ឧបត្ថម្ភបានមកពីណា?
**ចម្លើយ:** តាមគោលការណ៍របស់ILO និយោជកបង់ប្រាក់សោធន ចំនួនតិចបំផុត ៨% និយោជិកយ៉ាងតិច ៤%។ ទាក់ទងទៅនឹងការលំហែរមាតុភាព ប្រសិនជាអង្គការណាឲ្យលើសពី 50%ពិតជាប្រសើរណាស់គឺត្រូវតែឱ្យគេ ។ ហើយចំពោះការទទួលបាន70%នោះនៃប្រាក់ខែមួយលានពីរសែនចុះ។

11. **សំនួរ:**ប្រសិនបើគាត់មានសៀវភៅគ្រួសារ ហើយគ្មានអេតាស៊ីវិល(សំបុត្រចុះបញ្ជីអាពាហ៍ពិពាហ៍) តើអាចទទួលបានផលប្រយោជន៍ឬសោធនដែរឬទេ?
**ចម្លើយ:** មានតែអេតាស៊ីវិលតែមួយគត់អាចបញ្ជាក់បាន(គឺត្រូវអនុវត្តន៍តាមច្បាប់)។

12. **សំនួរ:** ក្រោយចេញសេចក្តីព្រាងច្បាប់របស់បសស តើកញ្ចប់សន្សំដែលបុគ្គលិកអង្គការសង្គមស៊ីវិលបានសន្សំទុកនៅក្នុងអង្គការរបស់គេ ហើយថារដ្ឋកាត់យកទាំងអស់ តើពិតដែរឬទេ?
**ចម្លើយ:** បសសធ្វើទៅតាមគោលការណ៍របស់ខ្លួនតែប៉ុណ្ណោះ

13. **សំនួរ:** ឧទាហរណ៍បុគ្គលិកបានទទួលប្រាក់សំន្សំ៥%នៃប្រាក់ខែរបស់គាត់នៅកន្លែងការងារ ។ តើប្រាក់សន្សំនេះយកទៅបង់ឲ្យបសសដែរ ឬ ទេ?
**ម្លើយ: គឺ**យកទៅបង់ឲ្យបសសតែ 4% ទេតែនៅពេលទទួលមកវិញបានដល់ 40%នៃប្រាក់សោធន។